សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែល: contact@licadho-cambodia.org

# សេចក្តីប្រកាសព័ត៌មាន

## អង្គការ លីកាដូ ថ្កោលទោសចំពោះការបង្ក្រាបដោយហិង្សាលើការដើរហែក្បួនអហិង្សារបស់អ្នកភូមិ ឡ ពាង

*ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤*

អង្គការ លីកាដូ មានការមិនពេញចិត្តជាខ្លាំង ចំពោះការបំបែកយ៉ាងហិង្សាទៅលើអ្នកភូមិជាង ៥០នាក់ មកពីសហគមន៍ ឡ ពាង ក្នុងខេត្តកំពង់ឆ្នាំង ដែលបានចាប់ផ្តើមដង្ហែក្បួន ដោយអហិង្សាចម្ងាយ ៦០គីឡូម៉ែត្រ មកកាន់រាជធានីភ្នំពេញ ដើម្បីអំពាវនាវរកដំណោះស្រាយសម្រាប់ទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃរបស់អ្នកទាំងនោះ។ អំឡុងពេលបំបែក អ្នកភូមិចំនួន ៣នាក់ (រួមទាំងប្តីរបស់តំណាងសហគមន៍ ឡ ពាង អ្នកស្រី អ៊ុំ សុភី) ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់សាលាដំបូងខេត្ត។

ការដង្ហែក្បួនដោយអហិង្សា ត្រូវបានបំបែកយ៉ាងហិង្សាពីសំណាក់ក្រុមនគរបាល និងកងរាជអាវុធហត្ថជាច្រើននាក់ ខណៈពេលអ្នកសហគមន៍កំពុងតែធ្វើដំណើរឆ្លងកាត់ព្រំប្រទល់ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល ត្រង់ចំណុចទីប្រជុំជនស្រុកកំពង់ត្រឡាច។ អ្នកភូមិសរុបចំនួន៨នាក់ត្រូវបានរងរបួស។

អ្នកភូមិចំនួន ៣នាក់ ដែលត្រូវបានចាប់ខ្លួន រួមមាន លោក សួន ញាណ (ប្តីរបស់អ្នកស្រី អ៊ុំ សុភី ជាអ្នកសហគមន៍ ឡ ពាង ដែលសកម្មជាងគេ) លោក ស្រ៊ុន ថា និងលោក គុជ ហុក (អាយុ ៦៧ឆ្នាំ ជាអ្នកភូមិដែលមានវ័យចាស់ជាងគេ)។

ការចាប់ខ្លួនចុងក្រោយនេះ កើតឡើងដោយសារតែទំនាស់ដីធ្លី ដែលបានកើតឡើងក្នុងឆ្នាំ ២០០១ នៅពេលដែលដីរបស់ប្រជាពលរដ្ឋចំនួន ១៩គ្រួសារ ត្រូវបានរំលោភបំពាន ហើយការរំលោភបំពាននេះ ត្រូវបានសម្របសម្រួលដោយលោក ថៃ ហ៊ី ជាអតីតមេភូមិ ដែលក្រោយមកគាត់បានក្លាយជាអ្នកតំណាងរបស់ក្រុមហ៊ុន ខេ.ឌី.ស៊ី ។ ក្រុមហ៊ុន ខេ.ឌី.ស៊ី បានអះអាង ថាខ្លួនជាម្ចាស់ដីរបស់ប្រជាពលរដ្ឋក្នុងឃុំតាចេះ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ក្រុមហ៊ុន ខេ.ឌី.ស៊ី នេះគ្រប់គ្រង ដោយអ្នកស្រី ជា ខេង ជាភរិយារបស់លោក ស៊ុយ សែម ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។

ករណីដីធ្លីនេះ បានកើតឡើងអស់រយៈពេលជាង ១៣ឆ្នាំមកហើយ ហើយបានប៉ះពាល់ដល់អ្នកភូមិឡ ពាង ជាង ១០០គ្រួសារ។ អំឡុងពេលនោះ អ្នកតំណាងរបស់សហគមន៍ និងមេភូមិម្នាក់ ត្រូវបានចាប់ដាក់ពន្ធនាគារ ក្នុងការចេញមុខតស៊ូមតិក្នុងនាមអ្នកភូមិដែលរងផលប៉ះពាល់។ អ្នកការពារសិទ្ធិ

មនុស្សមកពីអង្គការក្នុងស្រុកមួយឈ្មោះ សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) ត្រូវបានគេចោទថាមានជាប់ពិរុទ្ធភាពពីបទបរិហាកេរ្តិ៍ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១។

ការចាប់ខ្លួនអ្នកភូមិចំនួន ៣នាក់ នៅថ្ងៃនេះ ធ្វើឡើងក្រោយពេលដែលមានការប៉ះទង្គិចគ្នា រវាងអ្នកភូមិ និងកម្មករក្រុមហ៊ុនខេ.ឌី.ស៊ី កាលពីខែកក្កដា មុននេះ ខណៈពេលដែលក្រុមហ៊ុនកំពុងសាងសង់របងបេតុងកម្ពស់ ២ម៉ែត្រនៅព័ទ្ធជុំវិញដីមានជម្លោះ។ ក្រោយពីការប៉ះទង្គិច នោះអ្នកភូមិចំនួន ២នាក់ (លោក សៀង ហេង និងលោក ម៉ាង យ៉ាវ) ត្រូវបានចាប់ខ្លួន ហើយបច្ចុប្បន្ន ត្រូវបានគេឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។ មកដល់ថ្ងៃនេះ មិនទាន់មានកម្មកររបស់ក្រុមហ៊ុន ខេ.ឌី.ស៊ី ណាមួយត្រូវបានចាប់ខ្លួននោះទេ។

អំពើហិង្សាថ្មីៗនេះ រវាងអ្នកភូមិឡ ពាង និងក្រុមហ៊ុន ខេ.ឌី.ស៊ី គួរតែបានបញ្ជូនជាសញ្ញាអាសន្នទៅកាន់អាជ្ញាធរ ថាចាំបាច់ណាស់ត្រូវតែមានដំណោះស្រាយសម្រាប់ជម្លោះដីធ្លី ដែលបានកើតឡើងអស់រយៈពេលជាងមួយទស្សវត្សនេះ។ ជំនួសមកវិញ អាជ្ញាធររដ្ឋ នៅតែបន្តព្យាយាមគាបសង្កត់លើសម្លេងរបស់អ្នកភូមិ និងបន្តគំរាមកំហែងអ្នកសហគមន៍ដោយការចាប់ខ្លួនមនុស្សបន្ថែមទៀត។

លោក អំ សំអាត អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ បានមានប្រសាសន៍ថា៖ "ច្បាស់ណាស់ថា ជម្លោះដីធ្លីជាងមួយទស្សវត្សនេះនឹងមិនបញ្ចប់ដោយសារតែការវាយដំ និងការចាប់ខ្លួនអ្នកភូមិជាច្រើននាក់ យ៉ាងហិង្សាបន្ថែមទៀតបែបនេះនោះទេ"។ លោកបានបន្ថែមថា៖ "បញ្ហានេះ ត្រូវបានគេនិយាយពីមុនហើយឥឡូវវាហួសពេលណាស់ទៅហើយ ដែលរាជរដ្ឋាភិបាល ទើបដឹងថាជម្លោះដីធ្លីដែលមិនបានដោះស្រាយ គឺជាការគម្រាមកំហែងដល់ស្ថេរភាពសង្គមកម្ពុជា ហើយរាជរដ្ឋាភិបាលត្រូវតែដោះស្រាយ ដូចនេះប្រជាពលរដ្ឋអាចនឹងត្រូវបានគេផ្តល់នូវសិទ្ធិដីធ្លីដែលអ្នកទាំងនោះ សមនឹងទទួលបាន"។

## *សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក អំ សំអាត អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ
ទូរស័ព្ទលេខ៖ ០១២ ៣២៧ ៧៧០